អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ | Coalition for Partnership in Democratic Development

# សេចក្តីប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤

---

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល

លេខាធិការដ្ឋាន របស់ សម្ព័ន្ធភាព CPDD មានកិត្តិយសសូមជម្រាបជូនលោក លោកស្រី នាងកញ្ញា ដែលជានាយកប្រតិបត្តិ នាយិកាប្រតិបត្តិ ប្រធាន ឬតំណាងសមាជិកទាំងអស់មេត្តាជ្រាបថា អនុលោមតាមមាត្រា ២១ នៃលក្ខន្តិកៈរបស់ សម្ព័ន្ធភាព CPDD ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២២ សម្ព័ន្ធភាព CPDD នឹងត្រូវរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិ០៣ (បី) ឆ្នាំ (២០២៥-២០២៧) ដើម្បីបន្តដឹកនាំ សម្ព័ន្ធភាព CPDD។ សមាជិកក្រុមប្រឹក្សាភិបាល ដែលនឹងត្រូវជ្រើសរើសចេញពីការបោះឆ្នោតនេះយ៉ាងតិចចំនួន ០៥ (ប្រាំ) រូប និងមានអាណត្តិ ០៣ (បី) ឆ្នាំ។

ការបោះឆ្នោតនេះ នឹងប្រព្រឹត្តទៅនៅ **ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង ១៥:00 នាទីរសៀល** នៅកិច្ចប្រជុំសមាជិកសម្ព័ន្ធភាព CPDD ប្រចាំត្រីមាសទី០៣។

ប្រសិន បើលោក លោកស្រី នាងកញ្ញា ដែលជានាយកប្រតិបត្តិ នាយិកាប្រតិបត្តិ ប្រធាន ឬតំណាងជាសមាជិកទាំងអស់ មានចំណាប់អារម្មណ៍ក្នុងការឈរឈ្មោះជាបេក្ខជន បេក្ខនារី ការបោះឆ្នោតនេះ សូមបំពេញពាក្យសុំឈរឈ្មោះ តាមទម្រង់ដែលបានផ្តល់ជូន និងភ្ជាប់ជាមួយប្រវត្តិ រូបសង្ខេប (CV) ផ្ញើមកលេខាធិការដ្ឋាន របស់ សម្ព័ន្ធភាព CPDD ដែលមានអាសយដ្ឋាននៅលេខាធិការដ្ឋានសម្ព័ន្ធភាព CPDD ឬផ្ញើតាមអ៊ីម៉ែល secretariat@cpddcambodia.org ឲ្យបានមុន **ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២៤ វេលាម៉ោង១៧:០០ល្ងាច**។

អាស្រ័យហេតុនេះ ក្នុងស្មារតីសហប្រតិបត្តិការដើម្បីលើកស្ទួយគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អនៅកម្ពុជា យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី នាងកញ្ញា ពិតជានឹងចូលរួមឈរឈ្មោះជាបេក្ខជន បេក្ខនារី ក្នុងតួនាទីជាថ្នាក់ដឹកនាំនៃ សម្ព័ន្ធភាព CPDD។

សូមលោក លោកស្រី នាងកញ្ញា មេត្តាទទួលនូវការគោរពរាប់អានយ៉ាងជ្រាលជ្រៅអំពីខ្ញុំ។

ចម្លងជូន៖

- អង្គការសមាជិក
- ក្រុមប្រឹក្សាភិបាល
- គណៈកម្មាធិការប្រតិបត្តិ
- លេខាធិការដ្ឋាន
- ម្ចាស់មូលនីធិ និងអង្គការដៃគូពាក់ព័ន្ធ
- ឯកសារ-កាលប្បវត្តិ

ទម្រង់បំពេញពាក្យ

អង្គការសម្ព័ន្ធភាព ដៃគូដើម្បី ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យ

Coalition for Partnership in Democratic Development

# ឧបសម្ព័ន្ធ "ក"

# រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់ក្រុមប្រឹក្សាភិបាល

## ខែមករា ឆ្នាំ២០២២

# ជំពូកទី ៤
# រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់ក្រុមប្រឹក្សាភិបាល

## ប្រការ ២០._ អំពីក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសមាជិកយ៉ាងតិច ០៥ (ប្រាំ) រូប និងមានអាណត្តិ ០៣ (បី) ឆ្នាំ។ នៅពេលបញ្ចប់អាណត្តិនីមួយៗ សមាជិកក្រុមប្រឹក្សាភិបាលចាស់មានសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតជាថ្មីទៀតបាន ដែលមានតួនាទី និង ភារកិច្ចដូចខាងក្រោម៖

- បង្កើតទស្សនៈវិស័យនិងទិសដៅជាយុទ្ធសាស្រ្តសម្រាប់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យ (CPDD) បន្ទាប់ពីពិភាក្សាជាមួយសមាជិករួចដើម្បីធានាថាសំឡេង បញ្ហាអទិភាព និងតម្រូវការ របស់ពួកគេនឹងត្រូវបានដាក់បញ្ចូល
- ធ្វើការសម្រេចលើការបង្កើតគណៈកម្មការ ក្រុមការងារ និងតែងតាំងសមាជិករបស់ខ្លួន
- ផ្តល់ការណែនាំបែបយុទ្ធសាស្រ្តស្តីពីការអភិវឌ្ឍ និងការអនុវត្តផែនការប្រចាំឆ្នាំរបស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD) និងធ្វើការគាំទ្រការអនុវត្ត និងត្រួតពិនិត្យការរីកចម្រើនរបស់អង្គការសម្ព័ន្ធភាព ដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)
- អនុម័តលើការផ្លាស់ប្តូរនានានៃផែនការប្រចាំឆ្នាំរបស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាម បែបប្រជាធិបតេយ្យ (CPDD)
- អនុម័តផែនថវិកាទាំងអស់របស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(CPDD)
- អនុម័តរបាយការណ៍សម្រាប់ម្ចាស់ជំនួយ
- ចុះហត្ថលេខាលើឯកសារផ្លូវច្បាប់ក្នុងនាមតំណាងឱ្យអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ដោះស្រាយបញ្ហាទំនាស់ផ្សេងៗ របស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)
- ផ្តល់បច្ចេកទេសចំណេះដឹងផ្សេងៗ និងបទពិសោធន៍ដែលអាចប្រើប្រាស់បានដល់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)
- ធានាភាពស្របច្បាប់ និងនីត្យានុកូលភាពរបស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)
- ធ្វើការជ្រើសរើសប្រធានប្រតិបត្តិរបស់ អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)
- ព្យាយាមតាមដែលអាចធ្វើបានដើម្បីលើកកម្ពស់គោលដៅ និងគោលបំណងរបស់អង្គការសម្ព័ន្ធភាព

ដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(CPDD)
ដោយបង្កើតការផ្សព្វផ្សាយពីតួនាទី
និងដំណើរការរបស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យ (CPDD)។

បុគ្គលណាក៏ដោយដែលជាសមាជិក អាចឈរឈ្មោះជាបេក្ខជនសម្រាប់ការបោះឆ្នោតរបស់ក្រុមប្រឹក្សាភិបាល។ ការបោះឆ្នោតរបស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើឡើងដោយសេរី និងយុត្តិធម៌ និងធ្វើឡើង ដោយសំឡេងឆ្នោតសម្ងាត់។ ប្រធានប្រតិបត្តិត្រូវបូកសរុបសំឡេងឆ្នោត និងប្រកាសលទ្ធផលដល់ សមាជិកនានា ក្នុងកិច្ចប្រជុំពិសេសដែល មានការបោះឆ្នោតនោះ ។

ការមិនបន្តសមាជិកណាមួយអាចស្នើឡើងដោយសមាជិកពីររូប។ សំណើរនេះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីមូលហេតុនៃការស្នើរមិនឱ្យមានការបន្តនេះហើយត្រូវដាក់ជូនសមាជិក និងក្រុម ប្រឹក្សាភិបាល សម្រាប់ធ្វើការ ពិចារណា ។

សមាជិកដែលត្រូវបានគេស្នើរមិនឱ្យបន្តសមាជិកភាព ត្រូវមានឱកាសឆ្លើយតបដូចខាងក្រោម៖

- ឆ្លើយតប ជាលាយលក្ខណ៍អក្សរ
- ឆ្លើយតបដោយផ្ទាល់មាត់នៅក្នុងកិច្ចប្រជុំសមាជិកប្រចាំខែបន្ទាប់សេចក្តីសម្រេចចុងក្រោយថានឹងមិនបន្ត ត្រូវធ្វើឡើងដោយឆ្នោតពីរភាគបី (២/៣) នៃចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សាភិបាលរបស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(CPDD)។

  សមាជិកអាចចាកចេញដោយស្ម័គ្រចិត្ត បន្ទាប់ពីបាន ជូនដំណឹងជាលាយលក្ខ័ណ៍អក្សរដល់ប្រធានប្រតិបត្តិរួច។

សមាជិករបស់ក្រុមប្រឹក្សាភិបាលអាចលាលែង ពីក្រុមប្រឹក្សាភិបាលនៅពេលណាក៏បាន ដោយសារមូលហេតុ ណាមួយ ដោយជូនដំណឹងជាលាយលក្ខ័ណ៍អក្សររយៈពេល ០៣ ខែ ជាមុនដល់ប្រធានក្រុមប្រឹក្សាភិបាល
នៅក្នុងករណីដែលប្រធានជាអ្នកលាលែងវិញប្រធានប្រតិបត្តិត្រូវទទួលលិខិត លាលែង។ សមាជិកទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលដែលត្រូវបានសមាជិកពិចារណាថាកំពុងប្រព្រឹត្តផ្ទុយពីលក្ខខន្តិកៈរបស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(CPDD) ត្រូវតែ បញ្ឈប់ពីក្រុមប្រឹក្សាភិបាលនេះ។ ការបញ្ឈប់សមាជិករបស់ក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងដោយសំឡេង ឆ្នោត ២/៣ (ពីរភាគបី) របស់សមាជិក នៅក្នុងករណីមានការបញ្ឈប់ ឬការលាលែងរបស់សមាជិកណាមួយរបស់ក្រុមប្រឹក្សាភិបាលសមាជិកត្រូវបោះឆ្នោតជ្រើសរើសសមាជិកដើម្បីបំពេញកន្លែងនេះ នៅក្នុង កិច្ចប្រជុំប្រចាំត្រីមាស (មិនឱ្យហួសពី ៣ ខែ)។

**ប្រការ ២១._ អំពីសមាជិកក្រុមប្រឹក្សាភិបាល**

សមាជិកក្រុមប្រឹក្សាភិបាល ជ្រើសតាំងឡើងតាមការបោះឆ្នោតដោយសំឡេងគាំទ្រ២/៣ (ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាលរបស់អង្គការ និងមានសមាជិកយ៉ាងតិចចំនួន ០៥ (ប្រាំ) រូប រួមមានប្រធាន០១ (មួយ) រូប អនុប្រធាន ០១ (មួយ) រូប និងសមាជិក០៣ (បី) រូប។

**ប្រការ ២២._ អំពីប្រធានក្រុមប្រឹក្សាភិបាល**

ប្រធានក្រុមប្រឹក្សាភិបាល មានតួនាទីដឹកនាំក្រុមប្រឹក្សាភិបាល និងជាអ្នកទទួលបន្ទុកការងាររួមរបស់ អង្គការដូចខាងក្រោម៖

- អនុម័តលើការសម្រេចរបស់ក្រុមប្រឹក្សាភិបាល បន្ទាប់ពីកិច្ចប្រជុំផ្លូវការ
- កត់ត្រាកំណត់ហេតុកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- អនុម័តចំពោះការបន្ថែម និងកាត់សមាជិក
- បង្កើតការអញ្ជើញដល់សមាជិកក្រុមប្រឹក្សាភិបាល
- ធ្វើការផ្ទេរសិទ្ធជាប្រធានទៅឱ្យសមាជិកក្រុមប្រឹក្សាភិបាលក្នុងករណីអវត្តមាន។

ប្រធានក្រុមប្រឹក្សាភិបាល មានសិទ្ធិ និងកាតព្វកិច្ចតាមផ្លូវច្បាប់ចុះហត្ថលេខាឯកភាពលើឯកសារដូចខាង ក្រោម៖

១- គោលនយោបាយទាំងអស់របស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)

២- របាយការណ៍វឌ្ឍនភាពរាងរាល់ ៦ ខែ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សាវនកម្មក្នុងនិងក្រៅរបស់អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)

៣- គម្រោងសំណើរសុំជំនួយ និងឯកសារពាក់ព័ន្ធនានា

៤- ឯកសារស្របច្បាប់ដែលចាំបាច់មួយចំនួន រួមទាំងទម្រង់ផ្សេងៗដែលតម្រូវដោយរដ្ឋាភិបាលម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធដទៃទៀត។

**ប្រការ ២៣._ អំពីកិច្ចប្រជុំក្រុមប្រឹក្សាភិបាល**

ក្រុមប្រឹក្សាភិបាល ត្រូវជួបប្រជុំគ្នា ០១ដងក្នុងមួយខែ តាមការអញ្ជើញរបស់ប្រធានក្រុម ប្រឹក្សាភិបាល និងអាចប្រជុំជាវិសាមញ្ញបានតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ២/៣ (ពីរ ភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល។

**ប្រការ ២៤.–   អំពីលក្ខណៈគតិយុត្ត**

រាល់សេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលទាំងពីរប្រភេទ មានតម្លៃគតិយុត្តបាន លុះត្រាតែ មាន ការអនុម័តដោយសំឡេងគាំទ្រភាគច្រើនដាច់ខាត ៥០%+១ លើកូរ៉ុមចូលរួមក្នុង អង្គប្រជុំយ៉ាងហោចណាស់ ២/៣ (ពីរភាគបី) នៃសមាជិកក្រុមប្រឹក្សាភិបាល។

**អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ( CPDD)**

អង្គការសម្ព័ន្ធភាព
ដៃគូដើម្បី
ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យ

Coalition for
Partnership in
Democratic
Development

# ANNOUNCEMENT

16 July 2024

---

## BOARD OF DIRECTORS ELECTION

The CPDD Secretariat is pleased to inform you that the Executive Directors, President or Representative of all CPDD members, in accordance with article 21 of the CPDD Statute dated 27 October 2022, CPDD will hold a Board of Directors Election. For the mandate 2025-2027 to continue to govern CPDD. At least 5 (five) members of the Board of Directors shall be elected from this election and have a term of 3 (three) years mandate.

The election will take place on **September 27, 2024 at 3:00 PM** at the third quarterly meeting of CPDD Members 2024.

If you are interested in running for office, please fill out the application form provided and attach your resume (CV) send to CPDD Secretariat at CPDD Secretariat or email secretariat@cpddcambodia.org before **September 09, 2024 at 5:00 PM**.

Therefore, in the spirit of cooperation in promoting to nurture democratic accountability and good governance in Cambodia, we sincerely hope that you will definitely stand as a candidate in the leadership role of CPDD.

Please, ladies and gentlemen, have deep respect from us.

Copy to:

- CPDD Members
- CPDD Board of Directors
- CPDD Management Committee
- CPDD Secretariat
- Donors/Partners
- Documents - Chronology

Application Form